កុមាររៀន កុមារចេះ
ក ១២៣

# កូនឆ្កែនិងកូនឆ្មា



**កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា**

រឿង ៖ **កូនឆ្កែនិងកូនឆ្មា**

និពន្ធ និងរៀបរៀងដោយ ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**

វិចិត្ររូបភាពដោយ ៖ **អ្នកស្រី ម៉ាន់ ម៉ាឡែន**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

www.LetsReadAsia.org

កូនឆ្កែពពាលជាកូនឆ្កែឆ្លាត និងពូកែឆ្ងល់។
វាមានច្រមុះខុសគេ ហើយពូកែខាងហិតក្លិន។



កូនឆ្មាពណ៌លឿងជាកូនឆ្មាឆ្លាស និងខ្ជិលច្រអូស។
វាមានដៃឆ្វេងខុសគេ ហើយពូកែខាងច្រាន ។



កូនឆ្កែទើបតែមករស់នៅទីនេះ។



ចំណែកឯកូនឆ្មារស់នៅទីនេះយូរមកហើយ។



កូនឆ្មាមិនចូលចិត្តកូនឆ្កែទេ។

កូនឆ្មាគិតថា កូនឆ្កែធុំក្លិនឆ្អេះឆ្អាបខុសគេ។



កូនឆ្កែក៏ដឹងថាកូនឆ្មាមិនចូលចិត្តវាដែរ។
កូនឆ្កែគិតថា កូនឆ្មាមានឫកឆ្មើងឆ្មៃ និងឆ្មាស
ខុសគេ។



កូនឆ្មាច្រណែននឹងកូនឆ្កែដែលមានចំណី ច្រើនជាងវា។ ពេលខ្លះ កូនឆ្មាចាំលួចឆ្មក់ ឆក់ស៊ីចំណីរបស់កូនឆ្កែ។



កូនឆ្កែឃើញយ៉ាងច្បាស់ថា កូនឆ្មាលួចឆក់ស៊ី
ចំណីវា។ កូនឆ្កែឆ្ងល់ថា ហេតុអ្វីកូនឆ្មាស៊ីច្រើន
យ៉ាងនេះ?





កូនឆ្មាថា «ឯងនៅយាមទីនេះចុះ! យើងស៊ីឆ្អែតពេក ឥឡូវយើងងងុយដេកណាស់» ។

កូនឆ្កែឆ្ងល់ថា ហេតុអីកូនឆ្មាខ្ជិលច្រអូសយ៉ាងនេះ? វាមិនដែលចេះជួយការងារអីទេ។

កូនឆ្មាតែងតែលួចឆ្មក់ឆក់ស៊ីចំណីរបស់កូនឆ្កែជាច្រើនលើកច្រើនសា។



មុនដំបូង កូនឆ្កែមានចិត្តអំណត់។



លុះក្រោយមក កូនឆ្កែក៏ខឹងនឹងកូនឆ្មា។



កូនឆ្កែក៏រត់ដេញកូនឆ្មា។



កូនឆ្មារត់ឆ្លេឆ្លានៅក្រោមគ្រែ។



កូនឆ្កែឃ្មាតខ្មីរត់ដេញកូនឆ្មានៅក្រោមគ្រែ។



កូនឆ្មារត់ឆ្លេឆ្លានៅជុំវិញសួនច្បារ។

កូនឆ្កែឃ្មាតខ្មីរត់ដេញកូនឆ្មា

នៅជុំវិញសួនច្បារ។



កូនឆ្មារត់ឆ្លេឆ្លានៅក្រោមដើមក្រូចឃ្វិច។

កូនឆ្កែឃ្មាតខ្មីរត់ដេញកូនឆ្មានៅក្រោមដើម
ក្រូចឃ្វិច។



កូនឆ្មាចំអកថា «យើងជាកូនឆ្មាឆ្លាត និងរត់លឿនជាងឯង»។ កូនឆ្កែឮដូច្នេះ ក៏រត់ដេញកូនឆ្មាទៀត។



កូនឆ្មារត់ឆ្លេឆ្លា ក៏ប៉ះឈើច្រត់យាយ។



ពួកវារត់ដេញគ្នាទៅមក យាយក៏យកឈើច្រត់
ដេញសំពងសត្វទាំងពីរ។ កូនឆ្កែនិងកូនឆ្មា
ឃ្មាតខ្មីរត់យ៉ាងលឿន។



ពួកវានាំគ្នារត់ទៅដល់ក្រោមដើមក្រូចឃ្វិច។

ពួកវានៅតែចំអកដាក់គ្នាសូរខ្លាំងៗ ក៏ឮដល់ឃ្មុំ។





រ៉ូងឃ្មុំដេញទិចទាំងកូនឆ្កែនិងកូនឆ្មា។
កូនឆ្មារត់ដួលច្រងាប់ច្រងិល។
ឃ្មុំក៏ទិចដៃឆ្វេងរបស់កូនឆ្មា។



កូនឆ្កែក៏ជួយទាញកូនឆ្មាទៅពួនក្នុងឃ្លាំង។
កូនឆ្មាបានអរគុណកូនឆ្កែដែលបានជួយវា។



កូនឆ្មាក៏សុំទោសកូនឆ្កែ ដែលវាតែងតែច្រណែន។



ចាប់ពីពេលនោះមក ពួកគេក៏ចូលចិត្តលេង ជាមួយគ្នាវិញ។ ពួកគេរត់ដេញគ្នាលេង



នៅក្រោមគ្រែ

នៅក្រោមដើមក្រូចឃ្វិច



នៅជុំវិញសួនច្បារ



## ពន្យល់ពាក្យ

១. **ឆ្មាស** : ដែលចូលចិត្តរករឿងឈ្លោះប្រកែក

២. **ឆ្អេះឆ្អាប** : ដែលមានក្លិនស្អុយមិនល្អ

៣. **ឆ្មើងឆ្មៃ** : ដែលលេងឫក លេងខ្លួន

៤. **លួចឆ្មក់** : ដែលឆក់យករបស់ពីអ្នកដទៃ

៥. **ឆ្លេឆ្លា** : រត់ចុះរត់ឡើងដោយភ័យ



# សំណួរ

១. តើកូនឆ្កែពាលជាកូនឆ្កែយ៉ាងដូចម្ដេច? តើកូនឆ្មាលឿងជាកូនឆ្មាយ៉ាងដូចម្ដេច?

២. ហេតុអ្វីបានជាកូនឆ្កែ និងកូនឆ្មាតែងតែឈ្លោះគ្នា?

៣. នៅចុងបញ្ចប់រឿង ហេតុអ្វីបានជាកូនឆ្កែ និងកូនឆ្មាឈប់ឈ្លោះគ្នា?

៤. តើកូនធ្លាប់ឈ្លោះគ្នាជាមួយបងប្អូន និងមិត្តភក្តិរបស់កូនដែរឬទេ? តើកូនធ្វើដូចម្ដេចទើបឈប់ឈ្លោះគ្នា?






IPEA, Kg.Chhnang, 789 copies, SSK, Oct. 2022

បន្ទាប់ពីរៀនចប់មេរៀនទី៩ វំពូក **«ព្យញ្ជនៈផ្ញើជើង ឆ្ដ ឆ្គ ឆ្ព»** នៃសៀវភៅថ្នាក់ទី២ សិស្សនឹងអាចអានសៀវភៅរឿងនេះបានដោយខ្លួនឯង ដោយពុំចាំបាច់មានអ្នកដទៃជួយឡើយ។

ទោះជាយ៉ាងណា សិស្សថ្នាក់ទី១ ក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើលនិងរៀបរាប់អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះ ហើយអានពាក្យនិងតួអក្សរដែលពួកគេស្គាល់។

សូមចងចាំថា នៅពេលសិស្សចាប់ផ្ដើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែប្រសើរសម្រាប់ពួកគេ!



កម្មវិធីជាតិស្ដីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

9 789924 560371

បោះពុម្ពឆ្នាំ២០២២